រូបថត៖ Andreas Nilsson

*Joan, កើតនៅឆ្នាំ១៩៣៤*

ដើមឡើយ ខ្ញុំរស់នៅក្នុងជីវភាពជាអ្នកស្រឡាញ់ភេទផ្ទុយគ្នាតាមធម្មតា នៅក្នុងអ្វីដែលខ្ញុំបានជឿថា ជាបរិស្ថាននៃមនុស្សស្រឡាញ់ភេទផ្ទុយគ្នា ជារហូតមក រហូតដល់ពេលខ្ញុំចូលរៀននៅសាកលវិទ្យាល័យ។ នៅសហរដ្ឋអាមេរិក ពេលនោះ គេនៅតែហៅថា ខ្ទើយ ដដែល។ ខ្ញុំចាំថា ម្ដាយរបស់ខ្ញុំធ្លាប់បាននិយាយជាមួយនឹងបងប្អូនស្រីរបស់ខ្ញុំអំពីមិត្តភ័ក្តិម្នាក់របស់នាង។ គាត់និយាយថា នាងជាខ្ទើយ។ ប៉ុន្តែខ្ញុំមិនជឿថា គាត់ និងមនុស្សផ្សេងទៀតទាំងអស់នោះដឹងច្បាស់ថាខ្ញុំចង់មានន័យយ៉ាងណានោះទេ។

តាមពិតខ្ញុំបានទាក់ទងជាមួយនឹងក្រុមស្ត្រីស្រឡាញ់ស្ត្រីជាលើកដំបូង នៅពេលមានចលនាស្ត្រីនិយមនៅ Stockholm នៅដើមទសវត្សរ៍ទី ៧០។ មានក្រុមផ្សេងៗគ្នាជាច្រើនបានមកសួរសុខទុក្ខយើងនៅរដូវក្ដៅ ដោយក្រុមស្ត្រីនិយមអាមេរិកចង់បង្កើតទំនាក់ទំនងជាមួយនឹងក្រុមស្ត្រីនិយមនៅប្រទេសស៊ុយអែត។ ហើយពួកគេភាគច្រើន ជាស្ត្រីស្រឡាញ់ស្ត្រីតាំងពីកំណើតមកម្ល៉េះ។ ទោះបីជាយើងមិនបានទៅដល់ក្លឹបស្ត្រីស្រឡាញ់ស្ត្រីក៏ដោយ យើងបានឃើញពួកគេរាំជាមួយគ្នា ហើយយើងបានគិតថា ឱ! ព្រះអើយ! ធូរទ្រូងបន្តិច! អ្នកពិតជាអាចធ្វើវាបានមែន!

ប៉ុន្តែសម្រាប់ខ្ញុំវិញ វាក៏បានចាប់ផ្ដើមបន្តិចម្ដងៗ ខ្ញុំចាប់អារម្មណ៍កាន់តែខ្លាំងឡើងៗ។ ហើយនៅទីបំផុត ខ្ញុំក៏ចង់ចូលរួមក្នុង RFSL (សហព័ន្ធស៊ុយអែតដើម្បីសិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស មនុស្សស្រឡាញ់ទាំងពីរភេទ និងមនុស្សភេទទីបី) ប៉ុន្តែនៅពេលនោះ ពិតជាមិនអាចចូលរួមបានទេ បើគ្មានការណែនាំនោះ។ ខ្ញុំបានទៅដល់ទីនោះជាមួយនឹងមិត្តភ័ក្តិម្នាក់ដែលជាស្ត្រី។ ខ្ញុំបានសួរថា៖ តើពួកគេធ្វើម៉េចទៅទើបដឹងថា...? "អូ ពួកគេមិនសួរត្រង់ៗថា

អ្នកគេងជាមួយអ្នកណានោះទេ តែគេសួរថា អ្នកស្គាល់នរណាខ្លះ។″ ខ្ញុំបានស្គាល់ស្ត្រីប៉ុន្មាននាក់នៅក្នុងចលនាសេរីភាពស្ត្រីន័រវែស ហើយម្នាក់ក្នុងចំណោមពួកគេបាននិយាយថា ខ្ញុំទៅជាមួយគេ។ ខ្ញុំបានទទួលឯកសារមួយចំនួនដែលខ្ញុំអាចយកមកបង្ហាញបាន ហើយនេះគឺជាវិធីដែលខ្ញុំអាចចូលរួមក្នុង RFSL។ នៅទីនោះមានក្រុមស្ត្រីស្រឡាញ់ស្ត្រីមួយក្រុម ទើបតែបានចាប់ផ្តើមប៉ុណ្ណោះ។ វាត្រូវបានគេហៅថា ក្រុមយុវវ័យរ៉ិចតួរៀ ដែលចង់សំដៅទៅលើម្ចាស់ក្សត្រីរ៉ិចតូរៀ ដែលទ្រង់ជឿថា មិនចាំបាច់មានច្បាប់ប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រីឡើយ ដោយសារពួកនោះមិនមានឡើយ...

ខ្ញុំធ្លាប់ជាសមាជិកម្នាក់នៃក្រុមនេះ ប៉ុន្តែជីវិតសប្បាយជួបជុំនៅពេលនោះ មិនមានអ្វីពិសេសខ្លាំងទេសម្រាប់ខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ យើងបានចំណាយពេលយ៉ាងច្រើននៅភោជនីយដ្ឋានមួយកន្លែងឈ្មោះថា Piperska Muren។ នៅទីនោះ មានកន្លែងរាំពីរកន្លែង ដែលមួយកន្លែងមានសភាពអនាចារជាងមួយកន្លែងទៀត។ នេះហើយជាកន្លែងដំបូងដែលខ្ញុំ និង Eva បានទៅក្រៅជាមួយគ្នា គឺនៅដើមទសវត្សរ៍ទី ៧០។ Eva បានរស់នៅកន្លែងដ៏តូចមួយរបស់ខ្ញុំ មួយរយៈពេលខ្លី។ យើងបានដឹងថា យើងគឺជាគូស្នេហ៍ដ៏សក្តិសម នៅថ្ងៃដែលយើងសម្រេចចិត្តថាយើងត្រូវទូរសព្ទនិយាយគ្នាជានិច្ច ប្រសិនបើយើងមិនអាចទទួលទានអាហារពេលល្ងាចនៅផ្ទះបានទេ ជាជាងគ្រាន់តែទូរសព្ទនិយាយគ្នា តើយើងនឹងញ៉ាំអាហារពេលល្ងាចជាមួយគ្នាដែរឬទេ?

ខ្ញុំកំសាកខ្លាំងណាស់នៅពេលខ្ញុំប្រាប់ម្តាយរបស់ខ្ញុំ។ ខ្ញុំបានទៅលេងគាត់ ហើយនៅតាមផ្លូវត្រឡប់ទៅអាកាសយានដ្ឋានវិញ គាត់បានសួរខ្ញុំថា តើខ្ញុំមានទំនាក់ទំនងស្នេហាជាមួយនឹង Eva មែនទេ។ ខ្ញុំបានឆ្លើយថា មែន ហើយគាត់បានប្រតិកម្មតបថា៖ ប៉ុន្តែ ប្រហែលជាកូននឹងត្រូវណាត់ជួបបុរសនៅពេលក្រោយ មែនអត់? ខ្ញុំបានឆ្លើយតបថា មែនហើយ អ្នកម៉ាក់មិនយល់ទេ... ប៉ុន្តែគាត់បែរជាទទួលយកយើងទាំងពីរយ៉ាងឆាប់រហ័សមែនទែន ហើយគាត់ទទួលស្វាគមន៍

យើងណាស់ ពេលយើងទៅលេងគាត់។ ប៉ុន្តែ គាត់មិនដែលនិយាយថាគាត់មានអារម្មណ៍ពិតយ៉ាងណានោះទេ។

សព្វថ្ងៃនេះ មាននារីៗរាប់រយនាក់នឹងបង្ហាញខ្លួននៅពិធីជប់លៀងក្រុមស្ត្រីស្រឡាញ់ស្ត្រី នៅក្នុងឱកាសសប្តាហ៍បង្ហាញមោទនភាព (Pride Week) នៅ Stockholm ហើយខ្ញុំមានអារម្មណ៍ដូចជាច្រណែនបន្តិចដែរ ដោយគិតថា ពួកគេធ្វើវាបានយ៉ាងងាយស្រួល។ យើងនៅតែជឿថា យើងជាអ្នកត្រួសត្រាយផ្លូវសម្រាប់ពួកគេ។